ទំនុកដំកើង៤៩-៥០

# ជំពូក ៤៩

*ធាតុផ្សំ វាសនារបស់អ្នកអួតអាងពីទ្រព្យសម្បត្តិ*

គម្ពីរទំនុកដំកើងជំពូក៤៩ ជាផ្នែកមួយនៃមហាវគ្គនិក្ខមនំនៃព្រះគម្ពីរទំនុកដំកើងទាំងមូល។ កន្លងមកយើងឃើញរួចមកហើយ នូវផ្លូវរបស់ព្រះជាម្ចាស់ ទាក់ទងនឹងមនុស្សអាក្រក់ ហើយនិងមនុស្សសុចរិត។ មនុស្សដែលព្រះជាម្ចាស់បង្កើតមកនាំគ្នារស់នៅដាច់ឆ្ងាយពីព្រះជាម្ចាស់។ រាស្ត្ររបស់ព្រះអង្គដែលទ្រង់រើសតាំងក៏រស់នៅដាច់ពីព្រះអង្គដែរ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះអង្គបាននាំគេចេញពីទឹកដីដែលគេរស់ក្រោមនឹមទាសកម្ម។ ពេលរាស្ត្ររបស់ទ្រង់ឆ្លងកាត់ទុក្ខលំបាក ព្រះអង្គតែងតែយាងទៅសង្គ្រោះគេ។ យើងឃើញរឿងនេះក្នុងព្រឹត្តិការណ៍ដែលព្រះជាម្ចាស់ យាងទៅរំដោះរាស្ត្រទ្រង់ចេញពីទឹកដីប្រទេសអេស៊ីព្ទ។ រាស្ត្ររបស់ព្រះអង្គរស់នៅជាទាសកម្មក្រោមនឹមអ្នកដឹកនាំផ្តាច់ការ។

មិនតែប៉ុណ្ណោះ ជំពូក៤៩ បរិយាយពីភាពផ្ទុយគ្នារវាងផែនការរបស់ព្រះជាម្ចាស់ចំពោះមនុស្សអាក្រក់ និងចំពោះមនុស្សសុចរិត។ ជំពូកនេះ មិនបាននិយាយការពារជនទុច្ចរិតដែលឡើងធ្វើជាអ្នកមាន ក៏មិនបាននិយាយការពារដល់អ្នកក្រដោយអោយទ្រាំក្នុងទុក្ខលំបាករបស់ខ្លួនក៏ទេដែរ។ អំពើយុត្តិធម៌នឹងបង្ហាញការពិតជាមិនខាន។

ផ្ទុយទៅវិញ ជំពូកនេះ ពន្យល់ពីភាពគ្មានន័យចំពោះអ្នកមានដែលប្រមូលទ្រព្យដោយប្រើអំពើយុត្តិធម៌។ ឯវាសនារបស់គេ ក៏ត្រូវធ្លាក់ចុះដុនដាបដូចអ្នកក្រដទៃៗទៀតដែរ។ បើលោកអ្នកគិតថា ជំពូក៤៩ជាចលនាបដិវត្តន៍ក្នុងសង្គម រឿងនេះ ស្រេចនៅលើអ្នកជាអ្នកវិនិច្ឆ័យចុះ។ គម្ពីរនេះគ្រាន់តែចង់អោយលោកអ្នកពិចារណាសារជាថ្មីម្តងទៀតពីដំណើរដែលលោកអ្នកត្រូវរស់នៅក្នុងលោកនេះ។

> **១អស់ទាំងសាសន៍អើយ ចូរស្តាប់សេចក្តីនេះ មនុស្សទាំងឡាយ
> នៅលោកីយអើយ ចូរផ្ទៀងត្រចៀកស្តាប់ចុះ ២គឺទាំងធំទាំង តូច
> ទាំងមានទាំងក្រគ្រប់គ្នា ៣មាត់ខ្ញុំនឹងបញ្ចេញប្រាជ្ញា ហើយចិត្តខ្ញុំ
> នឹងរំពឹងគិតតែពីសេចក្តីត្រឹមត្រូវ ៤ខ្ញុំនឹងផ្ទៀងត្រចៀកស្តាប់ពាក្យ
> ឧបមា ខ្ញុំនឹងផ្តើមច្រៀងសេចក្តីអាថ៌កំបាំងរបស់ខ្ញុំតាមស្នូរស៊ុង
> (ទំនុកដំកើង៤៩:១-៤)។**

នៅក្នុងជំពូក៤៩ អ្នកកត់ត្រាបានប្រកូកប្រកាសសុំអោយមាបនវត្ថុគ្រប់បែបយ៉ាង ប្រុងប្រៀបនឹងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សេចក្តីអំពាវនាវបែបនេះ ឃើញមានសម្តែងក្នុងគម្ពីរអេសាយជំពូក១។ ចំណែកក្នុងគម្ពីរចោទិយកថា យើងឃើញមានសេចក្តីអំពាវនាវដូចគ្នានេះដែរ។ នៅពេលដែលព្រះជាម្ចាស់ទ្រង់នាំរាស្ត្ររបស់ព្រះអង្គចេញពីទឹកដីអេស៊ីព្ទ ទ្រង់ប្រគល់អោយគេទៅតាំងទីលំនៅក្នុងទឹកដីសន្យា។ ពេល

នោះ ព្រះអង្គបានកំណត់អោយស្ថានសួគ៌ និងផែនដីធ្វើជាសាក្សី។ ទ្រង់ប្រទានទឹកដីសន្យាអោយរាស្ត្ររបស់ទ្រង់ ដោយមានល័ក្ខខ័ណ្ឌយ៉ាងត្រឹមត្រូវ។ ឯល័ក្ខខ័ណ្ឌនោះទៀតសោត មានស្ថានសួគ៌ និងផែនដីធ្វើជាអ្នកជួយដឹងឮ។ ព្រះអង្គមានបន្ទូលក្នុងគម្ពីរចោទិយកថា៣២:១ថា "ឱផ្ទៃមេឃអើយ ចូរផ្ទៀងត្រចៀកចុះ ខ្ញុំនឹងបញ្ចេញវាចា ហើយសូមឱ្យផែនដីស្តាប់ពាក្យ ដែលចេញពីមាត់ខ្ញុំដែរ"។ បទនេះ ជាចម្រៀងរបស់លោកម៉ូសេ។ ព្រះជាម្ចាស់ប្រគល់ទឹកដីសន្យាអោយរាស្ត្ររបស់ទ្រង់ តែរាស្ត្ររបស់ទ្រង់ត្រូវរស់នៅក្រោមល័ក្ខខ័ណ្ឌដែលព្រះជាម្ចាស់ដាក់សម្រាប់គេ។ ឯល័ក្ខខ័ណ្ឌនោះទៀតសោត គឺគេត្រូវធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ។ ព្រះអង្គហៅស្ថានសួគ៌ និងផែនដីធ្វើជាសាក្សី ស្តីពីដំណើរនេះ។ ដោយសាររាស្ត្ររបស់ព្រះអង្គមិនបានស្តាប់បង្គាប់ដល់ទ្រង់ ប្រាំបីរយឆ្នាំក្រោយមកទៀត ទ្រង់បានបណ្តេញគេចេញពីទឹកដីសន្យា។ ដោយសារមូលហេតុនោះហើយ បានជាហោរាអេសាយកត់ត្រាទុកនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គបានហៅដល់ស្ថានសួគ៌ និងផែនដីអោយធ្វើជាសាក្សី ដ្បិតរាស្ត្ររបស់ព្រះអង្គបានធ្វើបាបទាស់នឹងព្រះអង្គ។ ការបណ្តេញរាស្ត្ររបស់ទ្រង់ចេញពីទឹកដីសន្យា ជាកិរិយាប្រព្រឹត្តដោយយុត្តិធម៌និងសុចរិតជាទីបំផុត។ ព្រះជាម្ចាស់បានធ្វើសម្រាប់រាស្ត្រទ្រង់។ រឿងនេះ មានសម្តែងនៅក្នុងគម្ពីរអេសាយ១:២។

ខាងក្រោមនេះ ជាការត្រាស់ហៅរបស់ព្រះជាម្ចាស់អោយមាបនវត្ថុនានាបើកត្រចៀកដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ។ ការត្រាស់ហៅនេះ ជាការត្រាស់ហៅដល់លោកអ្នកអោយបើកត្រចៀកដើម្បីស្តាប់ព្រះបន្ទូលព្រះអង្គដែរ។

**ហេតុអ្វីបានជាខ្ញុំត្រូវមានចិត្តភ័យខ្លាចក្នុងគ្រាអាក្រក់ គឺកាលណាសេចក្តីទុច្ចរិត ដែលតាមជាប់កែងជើងបានព័ទ្ធខ្ញុំជុំវិញហើយ (ទំនុកដំកើង៤៩:៥)។**

នៅក្នុងខខាងលើយើងឃើញមានអ្នកសួរ។ តើនរណាទៅជាម្ចាស់សំណួរ? តើជាសំណួររបស់អ្នកកត់ត្រាគម្ពីរទំនុកដំកើងនេះឬ? ឬមួយជាសំណួររបស់អ្នកមានដែលអួតអាងលើទ្រព្យសម្បត្តិរបស់ខ្លួន? ចុះបើមិនយ៉ាងដូច្នោះវិញ តើជាសំណួររបស់មនុស្សសុចរិតដែលមនុស្សអាក្រក់សង្កត់សង្កិនគេឬ? ខ្ញុំជឿថា សំណួរនេះ ជាសំណួររបស់អ្នកក្រមួយរូប។ ខ្ញុំហ៊ានចាត់ខ្លួនខ្ញុំបញ្ចូលក្នុងចំណោមអ្នកក្រដទៃៗទៀតដែរ។ ខ្ញុំខំរៀនសូត្រ ខំរកស៊ីធ្វើការតាមផ្លូវទៀងត្រង់។ ទោះបីធ្វើយ៉ាងនោះអស់ពីសមត្ថភាពហើយក៏ដោយ ក៏នៅតែមិនអាចរាប់ខ្លួនថា ជាអ្នកមាន បើប្រៀបនឹងអ្នកមាននៅក្នុងលោកនេះ។ ខ្ញុំចេះតែឆ្ងល់ថា តើអ្នកមានគេរកស៊ីរបៀបណា បានជាឆាប់មានម្ល៉េះ? បើគេរកស៊ីតាមផ្លូវខុសច្បាប់ដើម្បីធ្វើជាអ្នកមាន ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតអោយគេមានបានឆាប់ម្ល៉េះ? តើអនាគតរបស់គេនឹងទៅជាយ៉ាងណា? ហេតុអ្វីបានជាមនុស្សអាក្រក់ ប្រើផ្លូវវៀចវេរឡើងធ្វើអ្នកមាន ឬអ្នកធំបានយ៉ាងដូច្នេះ? នៅក្នុងប្រទេសនានាសព្វថ្ងៃ ត្រកូលអភិជនតែងចងសម្ពន្ធមិត្តជាញាតិផៅសន្តានតាមរយៈការរៀបការកូនចៅ។ យើងដឹងច្បាស់ណាស់ថា កិរិយាប្រព្រឹត្តរបស់គេ មិនមែនធ្វើតាមផ្លូវត្រង់ឡើយ។ នៅពេលឃោសនាបោះឆ្នោត គេខំប្រើគ្រប់មធ្យោបាយ ដើម្បីទប់អំណាច

របស់គេអោយនៅស្ថិតស្ថេរ។ ការប៉ុនប៉ងរបស់គេសុទ្ធតែបានសម្រេច ទោះបីគេប្រើមធ្យោបាយអយុត្តិធម៌ក៏ដោយ។ ហេតុអ្វីបានជាព្រះជាម្ចាស់បណ្តោយអោយគេរួចខ្លួនបានយ៉ាងងាយដូច្នេះ? ហេតុអ្វីបានជាព្រះជាម្ចាស់មិនព្រមធ្វើអ្វីមួយ ដើម្បីទប់ស្កាត់គេកុំអោយគេមានអភ័យឯកសិទ្ធិខ្ពស់ដល់ម្ល៉េះ? សូមយើងពិនិត្យមើលនៅក្នុងមេរៀនយើងតទៅទៀត តើវាសនារបស់អ្នកមានដែលអួតអាងពីទ្រព្យសម្បត្តិរបស់ខ្លួន នឹងទៅជាយ៉ាងណា?

> **៦ឯក្នុងពួកអស់អ្នកដែលទុកចិត្តនឹងរបស់ទ្រព្យខ្លួន ហើយអួតអាងពីទ្រព្យសម្បត្តិដ៏មានជាបរិបូរ ៧នោះគ្មានអ្នកណាមួយនឹងអាចលោះបងប្អូនខ្លួន ឬយកដំឡៃសំរាប់លោះគេទៅថ្វាយដល់ព្រះបានឡើយ (ទំនុកដំកើង៤៩:៦-៧)។**

អ្នកមានដែលអួតអាងលើទ្រព្យសម្បត្តិ មានព្រំដែននៅក្នុងជីវិតគេដែរ។ បទគម្ពីរខាងលើសម្តែងថា ម្យ៉ាងអ្នកមានមិនអាចទិញសេចក្តីសង្គ្រោះដល់ព្រលឹងរបស់ខ្លួនបាន។ សេចក្តីសង្គ្រោះស្រេចលើព្រះអម្ចាស់យេស៊ូវប្រទានដល់មនុស្សលោក។ ទោះបីយើងមានលុយ មានទ្រព្យសម្បត្តិ មានកេរ្តិ៍ឈ្មោះយ៉ាងណាក៏ដោយ យើងមិនអាចទិញសេចក្តីសង្គ្រោះសម្រាប់ព្រលឹងយើងបានជាដាច់ខាត។ អ្នកមាន មានលុយ ប៉ុន្តែមិនអាចទិញសេចក្តីសង្គ្រោះផ្ទាល់ខ្លួនបាន។ ឯអ្នកក្រវិញក៏ដូចគ្នាដែរ ដោយសារខ្លួនក្រ

ខ្លួនអាចទទួលសេចក្តីសង្គ្រោះបានដោយស្វ័យប្រវត្តិក៏ទេដែរ។ អ្នកមានណាដែលអួតអាងដោយប្រើទ្រព្យសម្បត្តិ ប្រើកេរ្តិ៍ឈ្មោះធ្វើអំពើល្អ ជននោះមិនអាចយកអំពើល្អរបស់ខ្លួនទៅដូរយកសេចក្តីសង្គ្រោះពីព្រះជាម្ចាស់បានឡើយ។ គម្ពីររ៉ូម៤:៥ សម្តែងថា "តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឱ្យមនុស្សទមិលល្មើសបានសុចរិត នោះសេចក្តីជំនឿរបស់អ្នកនោះ បានរាប់ទុកជាសេចក្តីសុចរិតវិញ"។ ឥឡូវ សូមយើងពិចារណាខខាងក្រោម។ នៅក្នុងអត្ថបទដើម អត្ថបទនេះសរសេរនៅក្នុងវង់ក្រចក។

**ដ្បិតដំឡៃលោះព្រលឹងគេ នោះថ្លៃពេកណាស់ ឥតដែលអាចនឹងលោះបានឡើយ (ទំនុកដំកើង៤៩:៨)។**

សេចក្តីសង្គ្រោះដល់ព្រលឹង មានតម្លៃរកអ្វីមកកាត់អោយស្មើពុំបាន។ ទោះបីធ្វើជាមហាសេដ្ឋីលើសេដ្ឋីនានាលើលោកយើងនេះ ក៏មិនអាចយកទ្រព្យសម្បត្តិរបស់ខ្លួនទៅដូរយកសេចក្តីសង្គ្រោះពីព្រះអម្ចាស់យេស៊ូវបានជាដាច់ខាត។

**នឹងឱ្យគេរស់នៅជាដរាប ឥតឃើញសេចក្តីពុករលួយមិនបានទេ (ទំនុកដំកើង៤៩:៩)។**

អ្នកមាន មានព្រំដែនសព្វបែបយ៉ាងដូចអ្នកក្រដែរ។ លុះដល់ត្រូវអស់អាយុ អ្នកមានត្រូវស្លាប់ដូចមនុស្សធម្មតាដែរ។ ទាក់ទងនឹងខខាងលើ ព្រះអម្ចាស់យេស៊ូវមានបន្ទូលជាពាក្យប្រៀបធៀបស្តីពីអ្នកមាន ហើយនិងលោកឡាសាក្នុងគម្ពីរលូកា១៦:១៩-៣១។ អ្នកមាន ទោះជននោះជានរណាក្តី មិនអាចជួយសង្គ្រោះខ្លួនបាន ក៏មិនអាចជួយផ្តល់សេចក្តីសង្គ្រោះដល់ជនណាម្នាក់ផ្សេងទៀតបានដែរ។ អ្នកមានមិនអាចទិញជីវិតអស់កល្បជានិច្ច ក្នុងព្រះអម្ចាស់យេស៊ូវបានជាដាច់ខាត។

**អើ គេនឹងឃើញពិតថា ពួកមនុស្សប្រាជ្ញក៏ស្លាប់ដែរ ហើយមនុស្សខ្លៅល្ងង់ នឹងមនុស្សកំរោល គេវិនាសទៅដូចគ្នា ព្រមទាំងចោលរបស់ខ្លួនទុកឱ្យអ្នកដទៃផង (ទំនុកដំកើង៤៩:១០)។**

ទោះលោកអ្នកជាអ្នកមានយ៉ាងកំពូលលើគេក្នុងលោកក៏ដោយ នៅពេលលោកអ្នកស្លាប់ លោកអ្នកបន្សល់ទុកទ្រព្យសម្បត្តិមហាសាលរបស់លោកអ្នក អោយអ្នកដទៃចាយជំនួសជាប្រាកដ។ បើលោកអ្នកមានគំនិតវាងវៃ លោកអ្នកប្រហែលជាអោយគេទុកទ្រព្យសម្បត្តិរបស់លោកអ្នកក្នុងទូរដែក រួចហើយដឹកទៅជាមួយលោកអ្នកបញ្ចុះក្នុងផ្នូរដើម្បីអោយលោកអ្នកដឹងក្នុងចិត្តប្រាកដថា ទ្រព្យសម្បត្តិរបស់ខ្ញុំ កាលនៅរស់ជារបស់ខ្ញុំ ស្លាប់ហើយក៏ជារបស់ខ្ញុំដែរ។ បើលោកអ្នកអាចធ្វើយ៉ាងដូច្នោះបាន លោកអ្នកអាចរក្សាទ្រព្យសម្បត្តិនៅជាមួយនឹងខ្មោចរបស់លោកអ្នកបាន។ ប៉ុន្តែ សូម

ជ្រាបថា មានព្រះមួយអង្គហ៊ានដកលោកអ្នកចេញពីទ្រព្យសម្បត្តិ ដែលលោកអ្នកយកទៅកប់ជាមួយ។ ព្រះមួយអង្គនោះ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ថ្ងៃមួយ ទេវតានៃសេចក្ដីស្លាប់ធ្វើដំណើរមកដល់ទ្វារបន្ទប់លោកអ្នក។ ទេវតានោះគោះទ្វារ រួចហើយចាប់យកលោកអ្នកទៅជាមួយ។ នៅពេលនោះ លោកអ្នកនឹងក្លាយត្រឡប់ទៅជាជនក្រីក្រដូចអ្នកក្រដទៃៗទៀតដែរ។

ប៉ុន្មានឆ្នាំកន្លងទៅ មានបុរសអ្នកមានម្នាក់ឈឺធ្ងន់រហូតដល់ទទួលមរណភាព។ បងប្អូនញាតិសន្ដានឈរចាំខាងក្រៅ ឃើញមេធាវីរបស់លោកចេញមក។ គេសួរថា "នៅពេលគាត់ស្លាប់ តើគាត់អាចយកអ្វីបានទៅជាមួយគាត់ខ្លះ? មេធាវីឆ្លើយថា "គាត់មិនអាចយកអ្វីទៅជាមួយបានទេ!" ដោយសារមូលហេតុនេះហើយ បានជាអ្នកកត់ត្រាគម្ពីរទំនុកដំកើងសម្ដែងថា "គេទុកទ្រព្យសម្បត្តិរបស់ខ្លួនអោយអ្នកដទៃ"។ ចំពោះលោកអ្នកដែលជាអ្នកមាន សូមបើកត្រចៀកដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកអ្នកមិនអាចទិញសេចក្ដីសង្គ្រោះបានឡើយ។ មិនតែប៉ុណ្ណោះ លោកអ្នកមិនអាចបន្ថែមអាយុជីវិតរបស់លោកអ្នក អោយរស់បានវែងជាងអាយុកំណត់ដែលព្រះជាម្ចាស់សម្រេចអោយលោកអ្នកទេ។ នៅថ្ងៃដែលលោកអ្នកលាចាកពីលោកនេះទៅ គំនរទ្រព្យសម្បត្តិរបស់លោកអ្នកលះចោលលោកអ្នកដែរ។ យើងខ្ញុំសូមលើកទឹកចិត្តដល់អ្នកមានថា មុននឹងស្លាប់គួរប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួន ដល់កិច្ចការងាររបស់ព្រះជាម្ចាស់ក្នុងការផ្សព្វផ្សាយព្រះបន្ទូល ដើម្បីអោយមនុស្សលោក ដែលមានសេចក្ដីត្រូវការបានឮផង។ បើលោកអ្នកជាគ្រីស្ទបរិស័ទអ្នកមាន កិរិយាប្រព្រឹត្តបែបនេះ ញ៉ាំង

អោយលោកអ្នកបានទទួលរង្វាន់យ៉ាងធំនៅឯបរលោកនាយ។

**អ្នកទាំងនោះគិតស្មានក្នុងចិត្តថា ពូជពង្សរបស់គេនឹងនៅជាប់ជានិច្ច ហើយថា ទីលំនៅគេនឹងធន់នៅគ្រប់ទាំងដំណតទៅ គេក៏ដាក់ឈ្មោះស្រុក តាមឈ្មោះរបស់ខ្លួនដែរ (ទំនុកដំកើង៩:១១)។**

នៅលើលោកនេះ អ្នកមាន អ្នកធំ ជាច្រើនរូបតែងតែចង់រក្សាឈ្មោះនាមរបស់គេអោយស្ថិតស្ថេរជានិច្ច ទោះបីគេស្លាប់ទៅហើយក៏ដោយ។ សេដ្ឋីម្នាក់ដែលជាអ្នកមាននៅលើលោកនេះឈ្មោះលោករ៉ុកកាហ្វេល័រ នៅលើលោកនេះ អគារសាធារណៈជាច្រើនមានឈ្មោះលោកឆ្លាក់នៅទីនោះ។ ប៉ុន្តែ យើងត្រូវសួរថា តើអគារទាំងនោះស្ថិតស្ថេរនៅបានរយៈប៉ុន្មាន? នៅពេលអគារទាំងនោះរលំ ឈ្មោះអ្នកទាំងនោះក៏ត្រូវរលាយបាត់អស់ពីផែនដីយើងនេះទៅដែរ។

**ប៉ុន្តែមនុស្សមិនស្ថិតស្ថេរនៅ ដោយមានកេរ្តិ៍ឈ្មោះទេ គឺគេដូចជាសត្វតិរច្ឆានដែលត្រូវវិនាសវិញ (ទំនុកដំកើង៤៩:១២)។**

អ្នកមាន អ្នកធំ នឹងត្រូវចូលទៅតាមផ្លូវមួយដូចមនុស្សដទៃៗទៀតដែរ។ ឯច្រកដែលត្រូវដើរចូលគឺ ទ្វារនៃសេចក្តីស្លាប់។ បន្ទាប់ពីពេលនោះទៅ រូបកាយរបស់គេ

ក្លាយទៅជាធូលីដីដូចដើមឡើងវិញ។

> **ឯផ្លូវគេ នោះសុទ្ធតែផ្ដេសផ្ដាសទទេ ប៉ុន្តែមនុស្សដែលកើតមកខាងក្រោយ ក៏ចូលចិត្តនឹងពាក្យសំដីរបស់គេដែរ – បង្អង់ (ទំនុកដំកើង៤៩:១៣)។**

ឃ្លាខាងក្រោមនេះ មានសារៈសំខាន់ណាស់។

> **គេដូចជាហ្វូងសត្វដែលដំរង់ទៅឯទីស្លាប់ សេចក្ដីស្លាប់នឹងស៊ីគេ ហើយមនុស្សទៀងត្រង់នឹងជាន់ឈ្លីគេតាំងពីព្រលឹម រូបល្អរបស់គេនឹងត្រូវសូន្យទៅ នៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ឥតមានទីអាស្រ័យឡើយ (ទំនុកដំកើង៤៩:១៤)។**

នៅក្នុងភាសាហេព្រើរពាក្យថា ស្ថានឃុំព្រលឹងមនុស្សស្លាប់ គេហៅថា ស្ហេអូល។ បន្ទាប់ពីស្លាប់ អ្នកមានប្រៀបឧបមាដូចជាហ្វូងសត្វ ដែលត្រូវយកទៅបោះចោលក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់។ បើនិយាយតាមន័យត្រង់ សេចក្ដីស្លាប់ជាអ្នកគង្វាលសម្រាប់អ្នកមានណាដែលគ្មានព្រះជាម្ចាស់គង់នៅជាមួយ។ ព្រះបាទដាវីឌសម្ដែងពាក្យផ្ទុយពីសេចក្ដីពិតខាងលើថា "ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះ

អ្វីសោះ" (ទំនុកដំកើង២៣:១)។ មិនតែប៉ុណ្ណោះ សាវ័កយ៉ូហានកត់ទុកថា "ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ" (១យ៉ូហាន៥:១២)។ អ្នកគង្វាលក្លែងក្លាយមានឈ្មោះថា សេចក្តីស្លាប់។ "សេចក្តីស្លាប់នឹងស៊ីគេ"។ ធម្មតាអ្នកគង្វាលពិតប្រាកដតែងតែរកស្មៅអោយចៀមរបស់ខ្លួនបានស៊ីឆ្អែត។ អ្នកគង្វាលរបស់អ្នកមានដែលគ្មានព្រះជាម្ចាស់ មានឈ្មោះថាសេចក្តីស្លាប់។ សេចក្តីស្លាប់ស៊ីសត្វរបស់ខ្លួន។ ឯសត្វនោះទៀតសោត គឺអ្នកមានដែលគ្មានសេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់។

មិនតែប៉ុណ្ណោះ ព្រះអង្គសម្តែងថា "រូបល្អរបស់គេនឹងត្រូវសូន្យទៅ នៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ឥតមានទីអាស្រ័យឡើយ"។ នៅលើលោកយើងនេះ មានគ្រឿងសម្អាងគ្រប់ប្រភេទ។ ទោះបីអ្នកមានសោភ័ណភាពស្រស់ល្អត្រកាល ដោយប្រើគ្រឿងសម្អាងទាំងនោះក៏ដោយ លុះដល់គេស្លាប់ទៅ យ៉ាងច្រើនបំផុតគេលាបគ្រឿងសម្អាងអោយអ្នកនោះ នៅពេលដែលគេតាំងសពអោយគេចូលមកសម្តែងគារវកិច្ចជាគ្រាចុងក្រោយបង្អស់។ បន្ទាប់ពីនោះទៅទៀត គ្រឿងសម្អាង និងរូបសម្ផស្សរបស់គេ ត្រូវរលាយសាបសូន្យស្អុយរលួយគ្មានសល់អ្វីឡើយ។ សេចក្តីស្លាប់មិនគោរពអ្នកក្រ មិនគោរពអ្នកល្អ ឬអ្នកអាក្រក់ជាដាច់ខាត់។

## ប៉ុន្តែព្រះទ្រង់នឹងលោះព្រលឹងខ្ញុំ ឱ្យរួចពីអំណាចនៃស្ថានឃុំព្រលឹង

**មនុស្សស្លាប់នោះវិញ ដ្បិតទ្រង់នឹងទទួលខ្ញុំទុក - បង្អង់ (ទំនុកដំកើង៤៩:១៥)។**

ចុងខនេះ មានពាក្យមួយថា "បង្អង់"។ ពាក្យនេះចង់អោយអ្នកអានផ្អាកមួយសន្ទុះ ដើម្បីគិតពិចារណាម្តងទៀតពីខ្លឹមសារនៃព្រះបន្ទូលរបស់ព្រះអង្គ ដែលទើបនឹងអានរួចមក។ ឯការដែលត្រូវពិចារណាគឺ ព្រះជាម្ចាស់តែមួយអង្គគត់ ដែលអាចផ្តល់សេចក្តីសង្គ្រោះដល់ព្រលឹងលោកអ្នក។ ទោះបីលោកអ្នកជាអ្នកមាន ឬអ្នកក្រក្តី លោកអ្នកមិនអាចធ្វើអ្វីអោយបានទទួលសេចក្តីសង្គ្រោះ ដោយខ្លួនលោកអ្នកផ្ទាល់បានទេ។ លោកអ្នកចាំបាច់ត្រូវទទួលជឿដល់ព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ ទើបលោកអ្នកទទួលបានសេចក្តីសង្គ្រោះ។ លោកអ្នកជាអ្នកមាន អាចទទួលសេចក្តីសង្គ្រោះដោយសារជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ឯអ្នកក្រក៏ត្រូវជឿលើព្រះអម្ចាស់យេស៊ូវ ទើបទទួលសេចក្តីសង្គ្រោះបាន។

**កុំឱ្យភ័យខ្លាច ដោយអ្នក១បានមានឡើង ក្នុងកាលដែលសេចក្តីរុងរឿងនៅផ្ទះបានបរិបូរនោះឡើយ (ទំនុកដំកើង៤៩:១៦)។**

សព្វថ្ងៃ យើងឃើញអ្នកមាន ទោះសម្លាប់គេ ទោះប្រព្រឹត្តអំពើសាហាយស្មន់ ទោះប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាងណាក៏ដោយ ដល់ពេលបោះឆ្នោត គេនៅតែ

ជាប់ឆ្នោតជានិច្ច។ នៅលើលោកនេះ អ្នកស្លូតតែងស្លាប់ អ្នកអាងចាក់កាប់ឡើងធ្វើអ្នកធំ។ ដោយសារមូលហេតុនេះហើយ បានជាយើងចាំបាច់ត្រូវស្រឡាញ់ព្រះអម្ចាស់យេស៊ូវគ្រិស្ត ដ្បិតទ្រង់ជាចៅក្រមលើអស់ទាំងចៅក្រម។ ទ្រង់វិនិច្ឆ័យរឿងក្តីរបស់អ្នកក្រ និងអ្នកមានដោយសុចរិតយុត្តិធម៌។ ទោះបីសព្វថ្ងៃ យើងមិនទាន់បានទទួលភាពយុត្តិធម៌នៅក្នុងជីវិតក៏ដោយ ថ្ងៃដែលព្រះអម្ចាស់យេស៊ូវកាត់ទោសដល់មនុស្សលោក យើងនឹងទទួលភាពយុត្តិធម៌ជាពិតប្រាកដ។

> **[១៧]ដ្បិតកាលណាគេស្លាប់ទៅ នោះនឹងយកអ្វីៗទៅផងមិនបាន ហើយសេចក្តីរុងរឿងរបស់គេនឹងមិនចុះទៅតាមឡើយ [១៨]ទោះបើអ្នកនោះបានរាប់ខ្លួនជាមានពរ ក្នុងកាលដែលនៅរស់នៅឡើយ ហើយបាននាំឱ្យមនុស្សសរសើរខ្លួន ដោយបានលៀងជីវិតយ៉ាងល្អក៏ដោយ [១៩]គង់តែនឹងត្រូវទៅតាមពួកឰយុកោខ្លួន ដែលមិនឃើញពន្លឺទៀត [២០]មនុស្សណាដែលមានកេរ្តិ៍ឈ្មោះ តែឥតមានយោបល់ នោះធៀបដូចជាសត្វតិរច្ឆាន ដែលវិនាសទៅនោះឯង (ទំនុកដំកើង៤៩:១៧-២០)។**

គេតែងពោលថា មនុស្សលោកកើតពីសត្វស្វា។ ផ្ទុយទៅវិញ ព្រះគម្ពីរមិនបានបង្រៀនយ៉ាងដូច្នោះទេ។ មនុស្សលោកកើតមកពីព្រះជាម្ចាស់។ ទ្រង់បង្កើត

គេមក។ ព្រះអង្គបង្កើតគេមកអោយមានលក្ខណៈដូចជារូបអង្គទ្រង់។ ប៉ុន្តែ មនុស្សលោកសម្រេចចិត្តប្រព្រឹត្តអំពើបាប បានជាធ្លាក់ពីសណ្ឋានដើម រហូតដល់មានលក្ខណៈដូចជាសត្វធាតុវិញ។ ព្រះអម្ចាស់បង្កើតសត្វដោយតម្រូវអោយត្រូវស្លាប់។ រីឯមនុស្សលោកដែលធ្លាក់ពីសណ្ឋានដើម មកដូចជាសត្វក៏ត្រូវស្លាប់ដូចគ្នាដែរ។ មនុស្សមិនបានធ្វើអំពើអ្វីមួយ ពីល្អល្មមទៅល្អគួរសមទេ។ មនុស្សលោកតែងប្រព្រឹត្តអំពើអាក្រក់មួយហើយមួយទៀតជាបន្តបន្ទាប់។ នៅក្នុងជីវិតជាក់ស្តែង មនុស្សតែងប្រព្រឹត្តអំពើផ្ទុយនឹងទ្រឹស្តី ដែលគេតែងពោលថា មនុស្សកើតមកពីសត្វ។ នៅលើលោកយើងនេះមានច្បាប់ទំនាញផែនដី។ ក្នុងច្បាប់ទំនាញផែនដី យើងឃើញថា អ្វីៗទាំងអស់សុទ្ធតែធ្លាក់ពីលើចុះទៅក្រោម។ ចំណែកច្បាប់ទំនាញសីលធម៌ក៏ដូចគ្នាដែរ មនុស្សលោកមានសីលធម៌ទាបទៅៗ បើប្រៀបធៀបទៅនឹងមនុស្សសម័យដើម។ ពាក្យចាស់បុរាណតែងនិយាយថា "មនុស្សជំនាន់ក្រោយដាក់បង្គោងឡើងដើមត្រប់"។ មនុស្សដាក់បង្គោងឡើងដើមត្រប់ មិនមែនដោយសារដើមត្រប់ខ្ពស់ទេ គឺដោយសារមនុស្សល្ងង់ បានជាមិនចេះបន្ទន់ដើមត្រប់បេះផ្លែ បែរជាដាក់បង្គោងឡើងទៅវិញ។

លោកអ្នកបងប្អូនអើយ បើឃើញមនុស្សទុច្ចរិតឡើងធ្វើជាអ្នកមាន ឬអ្នកធំ សូមកុំអោយឈឺក្បាលហាលថ្ងៃធ្វើអ្វី។

# ជំពូក ៥០

*បាឋចនា សេចក្ដីជំនុំជំរះ*

គម្ពីរទំនុកដំកើងជំពូក៥០ សរសេរដោយលោកអេសាភ។ លោកជាមេភ្លេងមួយរូបក្នុងចំណោមមេភ្លេងបីរូបទៀត ដែលមានលោកហីម៉ាន និងលោកអ៊ីថាន។ ជំពូក៥០ ជាគម្ពីរទំនុកដំកើងស្ដីពីសេចក្ដីជំនុំជំរះ។ ព្រះជាម្ចាស់យាងមកជំនុំជំរះរាស្ត្ររបស់ទ្រង់ ក៏ដូចជាជំនុំជំរះដល់ពួកមនុស្សអាក្រក់ដែរ។

**១ព្រះ គឺជាព្រះដ៏មានឥទ្ធិឫទ្ធិ ព្រះនាមជាព្រះយេហូវ៉ា ទ្រង់បាន**
**មានបន្ទូលហើយ ទ្រង់បានកោះហៅទាំងអស់ដែលនៅលើផែនដី**
**ចាប់តាំងពីទិសខាងថ្ងៃរះទៅដល់ទិសថ្ងៃលិច ២ព្រះទ្រង់បានភ្លឺមក**
**ពីក្រុងស៊ីយ៉ូន ដែលជាទីក្រុងមានលំអដ៏គ្រប់លក្ខណ៍ ៣ព្រះនៃ**
**យើងខ្ញុំទ្រង់យាងមក ហើយមិននៅស្ងៀមទេ មានភ្លើងឆេះនៅ**
**ចំពោះទ្រង់ ហើយនៅព័ទ្ធជុំវិញទ្រង់មានព្យុះសង្ឃរា (ទំនុកដំកើង**
**៥០:១-៣)។**

ព្រះជាម្ចាស់ជាព្រះដ៏មានមហិទ្ធិឫទ្ធិ នាមរបស់ទ្រង់គឺព្រះយេហូវ៉ា។ រាស្ត្ររបស់ទ្រង់គ្រប់រូបរង់ចាំព្រះនាមព្រះយេហូវ៉ា។

**ទ្រង់បង្គាប់ដល់ស្ថានសួគ៌នៅខាងលើ នឹងដល់ផែនដីដើម្បីជំនុំជំរះរាស្ត្ររបស់ទ្រង់ថា (ទំនុកដំកើង៥០:៤)។**

នៅថ្ងៃដែលព្រះអង្គធ្វើការជំនុំជំរះ ទ្រង់មានសាក្សីគ្រប់គ្រាន់សម្រាប់យកមកបញ្ជាក់ថា កិច្ចការងាររបស់ព្រះអង្គធ្វើទាំងអម្បាលមាណសុទ្ធតែមានភាពសុចរិត និងយុត្តិធម៌។

**ចូរប្រមូលពួកអ្នកបរិសុទ្ធរបស់អញ ឱ្យមកឯណេះ គឺជាពួកដែលបានតាំងសញ្ញានឹងអញ ដោយថ្វាយយញ្ញបូជា (ទំនុកដំកើង៥០:៥)។**

ពួកបរិសុទ្ធដែលព្រះទទួលដោយប្រើវិធីធ្វើយញ្ញបូជា ជាពួកកូនចៅសាសន៍អ៊ីស្រាអែល។

**នោះផ្ទៃមេឃនឹងសំដែងពីសេចក្ដីសុចរិតរបស់ទ្រង់ ដ្បិតគឺព្រះ**

**ហើយ ដែលជាចៅក្រម-បង្គង់ (ទំនុកដំកើង៥០:៦)។**

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់នឹងយាងមកធ្វើជាចៅក្រមជំនុំជំរះផែនដីយើងនេះ។ គម្ពីរយ៉ូហាន៥:២២ ក៏សម្តែងយ៉ាងដូច្នេះដែរថា "ព្រះវរបិតាទ្រង់មិនជំនុំជំរះអ្នកណាទេ ទ្រង់បានប្រគល់គ្រប់ការជំនុំជំរះដល់ព្រះរាជបុត្រាវិញ"។

**ម្នាលរាស្ត្រអញអើយ ចូរស្តាប់ចុះ អញនឹងពោល ឱអ៊ីស្រាអែលអើយ អញនឹងធ្វើបន្ទាល់ទាស់នឹងឯង អញជាព្រះ គឺជាព្រះនៃឯងហើយ (ទំនុកដំកើង៥០:៧)។**

ទាក់ទងនឹងខខាងលើ លោកអ្នកប្រហែលជាឆ្ងល់ថា ហេតុអ្វីបានជាព្រះជាម្ចាស់ មានព្រះហឫទ័យតឹងតែងចំពោះអ្នកដែលថ្វាយបង្គំព្រះអង្គនៅថ្ងៃអាទិត្យ។ ការទៅថ្វាយបង្គំព្រះអង្គរៀងរាល់ថ្ងៃអាទិត្យ ជាការល្អប្រសើរហើយ។ ប៉ុន្តែ កិរិយាដែលរាប់ថា ប្រសើរជាង គឺអ្នកថ្វាយបង្គំព្រះអង្គត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ បើអ្នកថ្វាយបង្គំ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយព្រះយេស៊ូវ កិរិយានោះ ជាកិរិយាដែលសព្វព្រះហឫទ័យដល់ព្រះជាម្ចាស់។

**៨ អញនឹងមិនបន្ទោសឯង ដោយព្រោះយញ្ញបូជា ដែលឯងថ្វាយ**

**នោះទេ ឯដង្វាយដុតរបស់ឯង នោះក៏នៅចំពោះអញជានិច្ច**
**៩ តែអញមិនយកគោឈ្មោលពីផ្ទះឯង ឬពពែឈ្មោលពីក្រោលឯង**
**ឡើយ ១០ ដ្បិតអស់ទាំងសត្វនៅព្រៃសុទ្ធតែរបស់អញ ព្រមទាំង**
**ហ្វូងសត្វ ទាំងប៉ុន្មាននៅលើភ្នំទាំងពាន់ផង (ទំនុកដំកើង៥០:៨-១០)។**

ទាក់ទងនឹងបទគម្ពីរខាងលើ លោកយេរេមាបានសម្តែងថា "ពីព្រោះនៅគ្រាដែលអញបាននាំពួកឰយុកោឯងរាល់គ្នា ចេញពីស្រុកអេស៊ីព្ទមក នោះអញមិនបាននិយាយនឹងគេ ឬបង្គាប់គេ ពីដំណើរដង្វាយដុត នឹងយញ្ញបូជាទេ គឺអញបានបង្គាប់សេចក្តីនេះដល់គេវិញថា ចូរស្តាប់តាមពាក្យអញ នោះអញនឹងធ្វើជាព្រះដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងបានជារាស្ត្ររបស់អញ ត្រូវឱ្យឯងរាល់គ្នាដើរតាមផ្លូវដែលអញបង្គាប់ឯងគ្រប់ចំពូក ដើម្បីឱ្យឯងបានសេចក្តីសុខស្រួល" (យេរេមា៧:២២-២៣)។ ចំណែកហោរាមីកា ក៏បានសម្តែងដែរថា "តើត្រូវឱ្យខ្ញុំយកអ្វី ដើម្បីចូលទៅចំពោះព្រះយេហូវ៉ា ហើយក្រាបថ្វាយបង្គំនៅមុខព្រះដ៏ខ្ពស់ តើត្រូវឱ្យខ្ញុំយកដង្វាយដុត ជាកូនគោអាយុ១ខួប ដើម្បីចូលទៅចំពោះទ្រង់ឬ តើព្រះយេហូវ៉ាទ្រង់នឹងសព្វព្រះហឫទ័យដោយចៀមទាំងពាន់ ឬដោយប្រេងទាំងម៉ឺនទន្លេឬអី តើត្រូវឱ្យខ្ញុំថ្វាយកូនច្បងខ្ញុំ ឱ្យបានធួននឹងអំពើរំលងដែលខ្ញុំប្រព្រឹត្ត គឺជាផលនៃរូបកាយខ្ញុំ ឱ្យបានធួននឹងបាបនៃព្រលឹងខ្ញុំឬ ឱមនុស្សអើយ ព្រះបានបង្ហាញឱ្យឯងស្គាល់សេចក្តីដែលល្អ តើព្រះយេហូវ៉ាសព្វ

ព្រះហឫទ័យឱ្យឯងប្រព្រឹត្តដូចម្តេច បើមិនមែនឱ្យប្រព្រឹត្តដោយសុចរិត ឱ្យស្រឡាញ់សេចក្តីសប្បុរស ហើយឱ្យដើរជាមួយនឹងព្រះនៃខ្លួន ដោយសុភាពរាបទាបប៉ុណ្ណោះ" (មីកា៦:៦-៨)។

**បើកាលណាអញឃ្លាន នោះអញមិនប្រាប់ដល់ឯង ពីព្រោះលោកីយ និងរបស់សព្វសារពើក្នុងលោកជារបស់ផងអញ (ទំនុកដំកើង៥០:១២)។**

បើព្រះជាម្ចាស់ទ្រង់មានព្រះហឫទ័យចង់សោយព្រះស្ងោយ ទ្រង់មិនប្រាប់អោយយើងដឹងទេ។

**ចូរអំពាវនាវដល់អញនៅថ្ងៃមានសេចក្តីទុក្ខលំបាក នោះអញនឹងជួយឱ្យរួច ឯងនឹងលើកដំកើងដល់អញ (ទំនុកដំកើង៥០:១៥)។**

សូមទុកចិត្តដល់ព្រះបន្ទូលព្រះអង្គចុះថា ព្រះជាម្ចាស់ពិតជាជំនុំជំរះដល់មនុស្សអាក្រក់។

**២១ អំពើនោះឯងបានធ្វើហើយ តែអញបាននៅស្ងៀមវិញ ឯងបាន**

**គិតស្មានថា អញដូចឯងតែប៉ុណ្ណោះ អញនឹងបន្ទោស ដោយរៀបរាប់អំពើឯង នៅចំពោះមុខ ២២ដូច្នេះ ឯងរាល់គ្នាដែលភ្លេចព្រះអើយ ចូរពិចារណាសេចក្តីនេះចុះ ក្រែងអញហែកឯងខ្ទេចខ្ទីទំលបើជួយផង (ទំនុកដំកើង៥០:២១-២២)។**

ព្រះអង្គមិនមែនមានព្រះបន្ទូលខាងលើ ទៅកាន់សាសន៍អ៊ីស្រាអែលប៉ុណ្ណោះទេ ព្រះអង្គមានបន្ទូលមកកាន់យើងរាល់គ្នា ដែលជាមនុស្សលោករស់នៅសព្វថ្ងៃនេះដែរ។ ប៉ុន្តែ ទោះជាព្រះអម្ចាស់ជំនុំជំរះអំពើបាបរបស់យើង ព្រះអង្គនៅតែមានព្រះហឫទ័យមេត្តាករុណាជានិច្ច។ ឯសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះអង្គបើសម្តែងនៅក្នុងសេចក្តីសង្គ្រោះដែលទ្រង់បានផ្តល់មកដូចខាងក្រោមនេះ។

**អ្នកណាដែលថ្វាយដង្វាយជាសេចក្តីអរព្រះគុណ នោះក៏លើកដំកើងអញដែរ ហើយអញនឹងសំដែងសេចក្តីសង្គ្រោះរបស់ព្រះដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់ (ទំនុកដំកើង៥០:២៣)។**

អ្នកណាដែលហ៊ានសារភាពទទួលស្គាល់កំហុស ព្រមទាំងយាងព្រះអម្ចាស់យេស៊ូវចូលមកគង់ធ្វើជាម្ចាស់ជីវិត និងជាអង្គសង្គ្រោះរបស់ខ្លួន អ្នកនោះទទួលបាន

សេចក្តីសង្គ្រោះដល់ព្រលឹងរបស់ខ្លួនជាពិត។

យើងស្ទេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ “ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!”